# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាអធិដ្ឋានពេញមួយយប់នៅបឹងទំពុន
# ថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៨

*កូនអើយ! មករកអ្វី?*

| |
|---|
| អត្ថបទទី១៖ ១យហ ៣,៧-១០ |
| ដំណឹងល្អ៖ យហ ១,៣៥-៤២ |

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងឃើញយ៉ូហានបាទីស្ទដែលជួយដើម្បីបង្ហាញអំពីព្រះគ្រីស្ត ដល់សិស្សពីរនាក់ដែលកំពុងធ្វើដំណើរជាមួយគាត់។ ថ្ងៃមុន យើងឃើញលោកយ៉ូហានបាទីស្ទដែលណែនាំឲ្យគេឆ្ងល់ដែលមានគណៈផារីស៊ី ក្រុមឡេវី ដែលទៅជួបគាត់នឹងសួរថា លោកជានរណា? មកធ្វើអ្វី? កំពុងនិយាយអំពីអ្នកណា? លោកយ៉ូហានបាទីស្ទ របៀបដែលគាត់រស់នៅ របៀបដែលគាត់ប្រកាសអំពីការកែប្រែចិត្តគំនិត របៀបដែលគាត់ធ្វើអគ្គសញ្ញាជ្រមុជទឹកឲ្យគេដើម្បីទទួលជីវិតថ្មី ណែនាំឲ្យប្រជាជន ឲ្យក្រុមឡេវី ក្រុមគណៈផារីស៊ី គេឆ្ងល់ យ៉ូហានបាទីស្ទណែនាំឲ្យគេសួរសំនួរ លោកជានរណា? ជាឱកាសមួយសម្រាប់យ៉ូហានបាទីស្ទ ដើម្បីបង្ហាញខ្ញុំមិនមែនជាព្រះគ្រីស្ត ប៉ុន្តែខ្ញុំនិយាយអំពីព្រះគ្រីស្តដើម្បីឲ្យគេចាប់អារម្មណ៍អំពីព្រះយេស៊ូគ្រីស្ត។

ថ្ងៃនេះយ៉ូហានបាទីស្ត គាត់មានសិស្សពីរនាក់ហើយគាត់សម្លឹងមើលព្រះយេស៊ូហើយនិយាយថា មើលហ្ន៎! លោកនេះហើយជាកូនចៀមរបស់ព្រះជាអម្ចាស់។ នៅពេលនោះសិស្សទាំងពីរនាក់របស់គាត់គេមើលតាមគាត់ហើយមើលឃើញព្រះយេស៊ូ។ នៅក្នុងគម្ពីរថ្ងៃនេះយើងឃើញអំពីរបៀបដែលព្រះយេស៊ូកំពុងត្រាស់ហៅយើង មុនគេបង្អស់ឥតមានពាក្យនិយាយតែមានសក្ខីភាពរបស់លោកយ៉ូហានបាទីស្ទ ដែលកំពុងសម្លឹងមើលព្រះយេស៊ូ ដើម្បីណែនាំឲ្យសិស្សពីរនាក់មើលតាមគាត់ដែលកំពុងសម្លឹងព្រះយេស៊ូដែរ។ មានរូបគំនូរខ្លះ ពេលគេគូរអំពីលោកយ៉ូហានបាទីស្ទ គឺគេគូររូបដែលលោកយ៉ូហានបាទីស្ទកំពុងចង្អុលព្រះយេស៊ូ ដើម្បីកុំឲ្យគេមើលលោកយ៉ូហានបាទីស្ទ ប៉ុន្តែគេមើលព្រះយេស៊ូដែលគាត់កំពុងចង្អុល។ នៅពេលសម្លឹងមើលព្រះយេស៊ូហើយ ព្រះអង្គចាប់ផ្តើមបង្កើតទំនាក់ទំនងដោយមានសំនួរ **អ្នកទាំងពីរមករកអ្វី?** ព្រះយេស៊ូដឹងច្បាស់ហើយគេកំពុងមើលព្រះអង្គ ប៉ុន្តែព្រះយេស៊ូបង្កើតសំនួរមួយដើម្បីបង្កើតទំនាក់ទំនង និងចាប់ផ្តើមសន្ទនាជាមួយអ្នកទាំងពីរនោះ អ្នកទាំងពីរមករកអ្វី? គេទូលព្រះអង្គថា តើលោកនៅកន្លែងណាខ្ញុំចង់ទៅ? គេចង់ដឹងព្រះយេស៊ូនៅកន្លែងណា? ព្រះយេស៊ូមានព្រះបន្ទូលដោយសម្លឹងមើលគេទាំងពីរនាក់ **សូមអញ្ជើញមកអ្នកនឹងបានឃើញ!** ព្រះយេស៊ូមិនបានពន្យល់ថា ខ្ញុំជាព្រះមែស៊ីនៅភូមិណាសារ៉ែតឬខ្ញុំជាព្រះគ្រីស្តដែលធ្វើដំណើរពីភូមិមួយទៅភូមិមួយដើម្បីប្រកាសដំណឹងល្អ... ព្រះអង្គនិយាយតែ

មួយឃ្លាថា សូមអញ្ជើញមកអ្នកនឹងបានឃើញ!។ គេក៏បានទៅឃើញកន្លែងដែលព្រះអង្គគង់នៅ ហើយគេក៏នៅជាមួយព្រះអង្គ។

នៅក្នុងគម្ពីរថ្ងៃនេះ យើងមើលឃើញអំពីរបៀបដែលព្រះជាម្ចាស់ត្រាស់ហៅ ទីមួយយើងសម្លឹងមើលព្រះយេស៊ូ ណែនាំឲ្យយើងឆ្ងល់ ទីពីរព្រះយេស៊ូសម្លឹងមើលយើង ព្រះយេស៊ូតបទៅអ្នកទាំងពីរនិងចាប់ផ្តើមមានទំនាក់ទំនងដើម្បីស្គាល់គ្នាទៅវិញទៅមក។ យើងដើរតាមព្រះយេស៊ូទៅដល់កន្លែងរបស់ព្រះអង្គ និងរស់នៅជាមួយព្រះយេស៊ូ ធ្វើដំណើរជាមួយព្រះយេស៊ូដើម្បីស្គាល់ជីវិតរបស់ព្រះយេស៊ូ ដើម្បីចូលយ៉ាងជ្រៅនៅក្នុងទំនាក់ទំនងយ៉ាងជិតស្និតជាមួយព្រះយេស៊ូ ដើម្បីទៅជាមិត្តសម្លាញ់របស់ព្រះយេស៊ូ។

បងប្អូនជាទីស្រឡាញ់!

យប់នេះ យើងត្រូវគិតពិចារណាដល់ជីវិតរបស់យើង យើងជាសិស្សសាលា យើងជានិស្សិត យើងរស់នៅក្នុងសង្គមបច្ចុប្បន្ននេះកុំឲ្យយើងភ្លេចយកពេលវេលាដើម្បីអង្គុយសម្លឹងមើលព្រះយេស៊ូ ដើម្បីព្រះយេស៊ូមានឱកាសសួរយើង **តើអ្នកមករកអ្វី?** រាល់ពេលយើងមានការអធិដ្ឋានជាឱកសមួយដើម្បីអង្គុយសម្លឹងមើលព្រះយេស៊ូ និងស្តាប់ព្រះសូរសៀងរបស់ព្រះយេស៊ូដែលកំពុងមានព្រះបន្ទូលដល់យើង តើអ្នកមករកអ្វី? នេះជាអ្វីដែលព្រះយេស៊ូត្រូវតែនិយាយគ្រប់ពេលវេលា ពេលយើងអង្គុយអធិដ្ឋាន ស្តាប់ព្រះគម្ពីរ គាំងព្រះកាយ មើលព្រះឈើឆ្កាង នៅពេលនោះព្រះយេស៊ូកំពុងមានព្រះបន្ទូលដល់យើង កូនអើយ! តើកូនមករកអ្វី? នៅក្នុងបុណ្យព្រះយេស៊ូប្រសូត ជាឱកាសមួយដែលយើងមានសម្រាប់យើងដែលជាព្រះសហគមន៍ ដើម្បីយើងចូលនៅក្នុងអាថទិកំបាំង នៅក្នុងគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ដែលបានចាប់កំណើតជាមនុស្ស ដើម្បីធ្វើដំណើរជាមួយយើងពីមួយថ្ងៃទៅមួយថ្ងៃ។ ហេតុនេះហើយ នៅពេលព្រះយេស៊ូជួបជាមួយយើង នៅពេលព្រះយេស៊ូសួរយើង មកពីពេលណា? មករកអ្វី? យើងមិននៅស្ងៀមស្ងាត់ យើងត្រូវតែសួរ តើព្រះអង្គនៅកន្លែងណា? តើព្រះអង្គទន្ទឹងរង់ចាំអ្វីខ្លះពីខ្ញុំ? នៅពេលនោះព្រះយេស៊ូឆ្លើយតែមួយឃ្លារថា សូមអញ្ជើញមកអ្នកនឹងបានឃើញ! យើងឃើញព្រះយេស៊ូដែលអធិដ្ឋាន ឃើញព្រះយេស៊ូធ្វើដំណើរពីភូមិមួយទៅភូមិមួយ ដោយមានព្រះហប្ញទ័យអាណិតអាសូរ ដល់អ្នកជំងឺ អ្នកក្រីក្រ ជនពិការ អ្នកដែលគ្មានទីពឹង គឺព្រះយេស៊ូដែលណែនាំឲ្យមហាជនមកជួបព្រះអង្គ ដោយសារគេចង់ទទួលសេចក្តីសង្ឃឹមថ្មី និងពន្លឺថ្មីនៅក្នុងជីវិតរបស់គេ។ បើយើងចង់ឃើញផ្ទាល់ភ្នែក យើងត្រូវតែយកពេលវេលា ដើម្បីអង្គុយ សម្លឹងមើល បើកត្រចៀកស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ ដែលព្រះអង្គបាននិយាយនៅក្នុងដួងចិត្តរបស់យើង។

នៅពេលពីរអ្នកបានទៅជាមួយព្រះយេស៊ូ គេមិននៅស្ងៀមស្ងាត់គេបានបន្តទៅរក លោកអន់ទ្រេទៅរកបងរបស់គាត់គឺលោកសិលា។ លោកសិលាបានទទួលការត្រាស់ហៅពីព្រះយេស៊ូដោយសារលោកអន់ទ្រេបានណែនាំឲ្យលោកសិលាស្គាល់ព្រះយេស៊ូ។ ដូច្នេះហើយឃើញទាំងអស់អំពីការត្រាស់ហៅ យើងមានអ្នកដែលចង្អុលបង្ហាញឲ្យយើងមើលព្រះយេស៊ូ ក្រោយមកគឺយើងផ្ទាល់ដែលកំពុងស្តាប់ មើលព្រះយេស៊ូនិងទទួលព្រះបន្ទូលរបស់ព្រះអង្គដូចព្រះនាងម៉ារី។ ក្រោយមក យើងជាអ្នកដឹកនាំដំណឹងល្អយ៉ាងពិសេស ដោយសារយើងបានអង្គុយជាមួយព្រះយេស៊ូ យើងបានស្គាល់ព្រះយេស៊ូ ហើយយើងចង់ឲ្យបងប្អូនឯទៀតៗស្គាល់ព្រះយេស៊ូតាមយើង ព្រោះយើងបានពោរពេញដោយអំណរសប្បាយ ដូចព្រះនាងម៉ារីនៅពេលគាត់បានទទួលដំណឹងល្អធ្វើជាមាតារបស់ព្រះយេស៊ូ គាត់បានទៅប្រាប់យាយអេលីសាប៉ែត ដោយសារដំណឹងល្អជាទ្រព្យសម្បត្តិមួយដែលយើងទុកមិនបាននៅក្នុងដួងចិត្តរបស់យើង ជាដំណឹងល្អដែលយើងត្រូវតែចែករំលែកជាមួយបងប្អូនឯទៀតៗ ដើម្បីបន្តឲ្យគេអញ្ជើញតៗគ្នា។ ២០០០ឆ្នាំហើយដែលព្រះសហគមន៍មានជីវិត ២០០០ឆ្នាំហើយដែលព្រះជាម្ចាស់ត្រាស់ហៅរបៀបនេះ ដោយយើងមានម្នាក់ដែលណែនាំឲ្យយើងស្គាល់ យើងសុខចិត្តអង្គុយដើម្បីជិតស្និទ្ធជាមួយព្រះយេស៊ូ នឹងក្រោយមកយើងទៅជាអ្នកដែលចង្អុលផ្លូវឲ្យអ្នកដទៃទៅរកព្រះយេស៊ូដែរ។

ដូច្នេះនៅក្នុងឆ្នាំថ្មី សូមព្រះជាម្ចាស់ប្រទានពរដល់យើងរៀងៗខ្លួន ជាពិសេសនៅយប់នេះឲ្យយើងបើកដួងចិត្តរបស់យើងដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ កូនអើយ! មករកអ្វី? អាម៉ែន៕